ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
លេខាធិការដ្ឋាន
លេខ ៣៤៦ ឧ.ក្រ.ច ២០០២

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**ជម្រាបចក**

**លោក លោកស្រីប្រធានតុលាការខេត្ត-ក្រុង និងចៅក្រមទាំងអស់**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការអនុវត្តន៍នីតិវិធីនៃការជំនុំជម្រះ ។

លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សូមជម្រាបលោក លោកស្រីថា តាមការចុះពិនិត្យនៅតាមតុលាការខេត្ត-ក្រុងមួយចំនួន និងការពិនិត្យករណីមួយចំនួនរបស់សម័យប្រជុំក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសង្កេតឃើញមានភាពមិនប្រក្រតីមួយចំនួនក្នុងការអនុវត្តន៍នីតិវិធីក្នុងការជំនុំជម្រះដូចជា ៖

ចៅក្រមជំនុំជម្រះមួយចំនួនមិនបានយកចិត្តទុកដាក់ ដាក់កម្មវិធីជំនុំជម្រះឱ្យបានទាន់ពេលវេលានូវសំណុំរឿង ដែលចៅក្រមស៊ើបអង្កេតបានបញ្ជូនមកឱ្យជំនុំជម្រះដែលជាហេតុធ្វើឱ្យថេរវេលា នៃការឃុំខ្លួនជាបណ្ដោះអាសន្ន ឬ រឿងក្ដីអូសបន្លាយ ឬ ហួសការកំណត់ច្បាប់ ។

ចៅក្រមជំនុំជម្រះមួយចំនួននៅពេលបញ្ចប់ដំណាក់កាលសួរដេញដោល ការសន្និដ្ឋានទោស និងការសន្និដ្ឋានការពារខ្លួនចប់សព្វគ្រប់ហើយ មិនបានប្រកាសផ្អាកសវនាការ ដើម្បីថយខ្លួនទៅពិចារណា ឬ ថយខ្លួនទៅបន្ទប់សម្ងាត់ ដើម្បីរៀបចំតាក់តែងសេចក្ដីសម្រេចនៃសាលក្រមទេ គឺប្រកាសសាលក្រមនៅពេលជំនុំជម្រះតែម្ដងហាក់ដូចជាសាលក្រមនោះបានរៀបចំទុកជាមុន ជាស្រេចមុននឹងប្រកាសបើកសវនាការ ។

ចៅក្រមជំនុំជម្រះមួយចំនួនទៀត ក្រោយពីបញ្ចប់ដំណាក់កាលសួរដេញដោល ការសន្និដ្ឋានទោស និងការសន្និដ្ឋានការពារហើយ បានប្រកាសលើកការប្រកាសសាលក្រមទៅថ្ងៃក្រោយ ហើយក្នុងអំឡុងពេលនោះបែរជាធ្វើការស៊ើបអង្កេតបន្ថែមដោយខ្លួនឯងលើគ្រប់ចំណុច ដែលចៅក្រមស៊ើបអង្កេតបានអង្កេតរួចហើយនោះ ។

ចំណាត់ការដូចរៀបរាប់ខាងលើ គឺជាការរំលោភទៅនឹងបទបញ្ញត្តិនៃមាត្រា ១៤១.១៤៥.១០៧ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងសារាចរលេខ ០៤ សរច ៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ស្ដីពីការណែនាំអំពីនីតិវិធីរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌ ។

សេចក្ដីដូចជម្រាបខាងលើ សូមលោក លោកស្រី ពិនិត្យពិចារណា និងខិតខំអនុវត្តនីតិវិធីជំនុំជម្រះឱ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ ។

សូម លោក លោកស្រី ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២

**វៀល មួន**

<u>ចម្លងជូន</u>

-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាស្ដីទីនៃមហាអយ្យការអមតុលាការកំពូល
- ប្រធានសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍
-ដើម្បីជូនជ្រាបជាព័ត៌មាន